# សីលប្រាំងាយចាំមិនភ្លេច

## សីលប្រាំជាកិច្ចអ្នកសាងកុសល *(បទកាកគតិ)*

*តើថ្ងៃណាទៅ ទើបបានកូនចៅ ភ្ញាក់ដឹងរូបា*
*កុំគិតតែដេក ធ្មេចភ្នែកច្រេះរាំ ត្រូវក្រោកហើយណា*
*សម្លឹងជ្រុងជ្រោយ ។*

*រកផ្លូវទៅមុខ ក្រែងបានក្តីសុខ កូនកុំបណ្តោយ*
*ឲ្យហួសកន្លង នាំតែស្តាយក្រោយ គិតគូរឲ្យហើយ*
*ទើបមិនវេទនា ។*

*ផ្លូវនោះមានប្រាំ ចូរកូនចំណាំ ចាំឲ្យច្បាស់ថា*
*មានតែព្រះធម៌ អាចនាំអាត្មា តាមក្បួនតម្រា*
*ថាបានក្តីសុខ ។*

*ព្រះពុទ្ធទ្រង់ញាណ យាងចូលនិព្វាន បានបន្សល់ទុក*
*នូវពុទ្ធោវាទ ហាក់ក្តោតគុក ដែលជាប្រមុខ*
*ឲ្យយើងចងចាំ ។*

*បញ្ចសីលា តាមខ្មែរភាសា ប្រែថាសីលប្រាំ*
*ជាពាក្យងាយស្រួល ក្នុងការចំណាំ តែភ្លេចបណ្តាំ*
*លែងខ្វីនឹកគិត ។*

បាណាតិបាត  កុំឲ្យប្រមាថ  សត្វមានជីវិត
កុំប៉ុនកុំប៉ង  កុំមានគំនិត  ប្រល័យជីវិត
សត្វនោះឲ្យសោះ ។

រាល់អស់រូបា  កើតមកហើយណា  តែងតែចង់រស់
ទាំងយើងទាំងគេ  ដូចគ្នាទាំងអស់  មិនថាទាបខ្ពស់
ធាត់ធំឬតូច ។

អទិន្នាទាន  កុំបីបំពាន  កុំប្លន់កុំលួច
កុំកេងប្រវ័ញ្ច  នាំតែឲ្យខូច  ទោះបីតិចតួច
ទ្រព្យអ្នកដទៃ ។

ទ្រព្យយើងទ្រព្យគេ  រកមកហូរហៃ  មិនថាយប់ថ្ងៃ
ដោយចេះគិតគូរ  និងចេះលកលៃ  ចេះទាំងសំចៃ
ទើបសល់ទុកបាន ។

បើគេមកប្លន់  លួចឆក់ទ្រព្យធន  នាំឲ្យក្ដៅប្រាណ
កុំចង់ចាក់កាប់  បកសងវិញថ្កាន  នោះទើបខ្លួនបាន
រំងាប់កំហឹង ។

លោកថាកាមេ  តែងអាស្រូវក្ដើ  នាំឲ្យគេខឹង
កុំឲ្យទាក់ទង  កុំខំសញ្ជឹង  គិតពីរឿងហ្នឹង
គ្មានបានផលអ្វី ។

ស្រីពាក់ពន្ធប្រុស	កុំប៉ះឲ្យសោះ	ប្ដីអ្នកដទៃ
នាំទុក្ខដល់ខ្លួន	ជារឿងចង្រៃ	ហើយសែនអប្រិយ៍
លោកឲ្យជៀសឆ្ងាយ ។

ឯប្រុស ៗ វិញ	លោកឲ្យជៀសចេញ	ស្រីអ្នកទាំងឡាយ
កុំធ្វើផ្ដេសផ្ដាស	នាំឲ្យអន្តរាយ	មិនបានសុខកាយ
ជារៀងរហូត ។

មុសាវាទា	កើតឡើងពេលណា	នាំឲ្យគេក្រោធ
ព្រោះពាក្យភូតភ	និងពាក្យបញ្ឆោត	ពុំដែលល្អសោត
គេអាចជឿបាន ។

ពាក្យភូតកុហក	ហៅសែនអាក្រក់	គេពុំរាប់អាន
គេលែងទុកចិត្ត	គេស្អប់ដល់ប្រាណ	ដល់អ្នកដែលបាន
ប្រើពាក្យមុសា ។

សុរាមេរយ (សុរាមេរ័យ) អស់ទាំងប្រុសស្រី នៅក្នុងលោកា
ព្រះកុំឲ្យសេព	នាំក្ដៅឱរា	ប៉ះវាពេលណា
ភ្លេចភ្លាំងស្មារតី ។

មិនថាចាស់ក្មេង	ធ្វើឲ្យវង្វេង	លែងជាប្រក្រតី
លែងស្គាល់ម៉ែឪ	បងប្អូនប្រុសស្រី	បានឈ្មោះអប្រិយ៍
ខូចទ្រព្យផ្សេងៗ ។

*សីលទាំងប្រាំនេះ បើអ្នកណាចេះ រក្សាខ្ជាប់ខ្ជួន*
*ព្រះថាបានសុខ និងបានរួចខ្លួន ឱ:ឱកូនស្ងួន*
*ចូរកាន់ឲ្យបាន ។*

*ដល់ពេលស្លាប់ទៅ ព្រលឹងកូនចៅ ទៅសួគ៌និព្វាន*
*ជាកន្លែងសុខ លើសអស់សព្វឋាន គឺសួគ៌វិមាន*
*នោះឯងហើយណា ។*

*នៅទីបញ្ចប់ ខ្ញុំសូមគោរព ព្រះធម៌ថ្លៃថ្លា*
*ដែលប្រៀនប្រដៅ ជនគ្រប់រូបា ត្រិះរិះសិក្សា*
*រំលឹកព្រះគុណ ។*

*អាចជួយរំដោះ អស់ទាំងបាបគ្រោះ ទោះស្រាលឬធ្ងន់*
*បើយើងកាន់បាន សែនល្អពេកពន់ បានសុខដល់ខ្លួន*
*របូតទៅហោង ៕*

